ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ/បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីបទប្បញ្ញត្តិបន្ថែមលើអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

**មាត្រា ២ .- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងចែងពីលក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់សហគ្រាសសាធារណៈដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

**មាត្រា ៣ .- វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសសាធារណៈដែលបោះផ្សាយលក់មូលបត្រជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## លក្ខខណ្ឌ និងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់សហគ្រាសសាធារណៈ

**មាត្រា ៤.- ការស្នើសុំការអនុញ្ញាតបោះផ្សាយលក់មូលបត្រជាសាធារណៈ**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលតាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីការផ្តល់យោបល់របស់ក្រុមប្រឹក្សាភិបាល ឬត្រូវមានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

ដោយឡែក ចំពោះគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ ឬសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ត្រូវចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ជាធរមាន ។

**មាត្រា ៥.- ការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ដែលទទួលបានការអនុញ្ញាតជាគោលការណ៍ ឬមានសេចក្តីសម្រេចពីរាជ-រដ្ឋាភិបាលឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវរៀបចំបែបបទស្នើសុំការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៦.- ការចុះបញ្ជីភាគកម្មសាធារណៈ**

ក្រោយពីបានបញ្ចប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ឈ្មោះភាគហ៊ុនិកនៃភាគកម្មសាធារណៈឱ្យគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ។

## ជំពូកទី ៣

## អភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

**មាត្រា ៧.- ការអនុវត្តអភិបាលកិច្ចសាជីវកម្ម**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវធានានូវសិទ្ធិផ្សេងៗរបស់គ្រប់ភាគហ៊ុនិក និងអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម ដែលមានជាធរមាន ។

**មាត្រា ៨.- គោលការណ៍រៀបចំក្រុមប្រឹក្សាភិបាល**

សហគ្រាសសាធារណៈដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវរៀបចំសមាសភាពក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសហគ្រាសសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម ដោយមាននូវអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនដូចមានកំណត់ក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ៩.-សមាសភាពក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលរបស់សហគ្រាសសាធារណៈ ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវមានសមាសភាព ដូចខាងក្រោម ÷

-តំណាងក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ០១ រូប

-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប

-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាងនៃក្រសួង/ស្ថាប័ន/អង្គភាព ដែលមានសារៈសំខាន់សម្រាប់សាមីសហគ្រាសសាធារណៈ ០១ រូប

-តំណាងនិយោជិត ០១ រូប

-អគ្គនាយកសហគ្រាសសាធារណៈ ០១ រូប

-អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ០១ រូប

-អភិបាលឯករាជ្យ ០១រូប ឬ ០២រូប ក្នុងករណីដែលមិនអាចជ្រើសរើសបាននូវអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។

**មាត្រា ១០.- ការតែងតាំងអណត្តិគាហកៈ**

ភាគហ៊ុនិកនៃភាគកម្មសាធារណៈ អាចចាត់តាំងអណត្តិគាហកៈ ០១ (មួយ) រូប ជាតំណាងភាគកម្មសាធារណៈ ដើម្បីចូលរួមបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិករបស់គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១១.- បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលគ្រប់រាជធានី-ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មេសា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ